Carers NSW AUSTRALIA

# កិច្ចបំរើសំរាប់អ្នកមើលថែនៃរដ្ឋញូសៅវែល

## តើអ្នកមើលថែជានរណា?

អ្នកមើលថែគឺជាសាច់ញាតិ និងមិត្តភក្តិដែលកំពុងតែមើលថែជនដែលមានពិការភាព ជំងឺសរសៃប្រសាទ ជំងឺរ៉ាំរ៉ៃ ឬជនដែលមានអាយុជរា។ លោកអ្នកអាចជាអ្នកមើលថែប្តី ប្រពន្ធ ឪពុក ឬម្តាយ កូន ជីដូន ឬជីតា ចៅ ឪពុកមា ម្តាយមីង អ្នកជិតខាង ឬមិត្តភក្តិរបស់លោកអ្នក។ ការមើលថែមិនមែនជារឿងងាយស្រួលរហូតនោះទេ។ ប្រហែលជាមានសំណួរជាច្រើនដែលលោកអ្នកចង់សាកសួរដូចជា:

- ខ្ញុំទើបតែក្លាយទៅជាអ្នកមើលថែ — តើខ្ញុំចាប់ផ្តើមពីណាទៅ?
- តើជំនួយផ្នែកថវិការអ្វីខ្លះដែលខ្ញុំអាចទទួលបាន?
- តើខ្ញុំអាចពិភាក្សាជាមួយអ្នកណាម្នាក់អំពីអារម្មណ៍របស់ខ្ញុំបានឬទេ?
- តើកិច្ចបំរើអ្វីខ្លះដែលអាចជួយយើងបាន?
- តើខ្ញុំអាចជួបអ្នកដែលមានស្ថានភាពដូចខ្ញុំយ៉ាងដូចម្តេចទៅ?
- តើខ្ញុំគ្រប់គ្រងភារកិច្ចមើលថែ និងភារកិច្ចដ៏ទៃទៀតយ៉ាងដូចម្តេចទៅ?
- តើខ្ញុំអាចទទួលបានការឈប់សំរាកដែលមានលទ្ធផលល្អសំរាប់ខ្ញុំ និងអ្នកដែលខ្ញុំមើលថែយ៉ាងដូចម្តេចទៅ?
- តើខ្ញុំចាំបាច់ត្រូវបោះបង់ចោលការងារឬទេ?

## តើកិច្ចបំរើ និងជំនួយអ្វីខ្លះដែលមានសំរាប់ខ្ញុំ?

ជំនួយអាចជួយលោកអ្នក ក៏ដូចជាអ្នកដែលលោកអ្នកមើលថែដែរ។ ឧទាហរណ៍នៃកិច្ចបំរើមួយចំនួនមានដូចជា:

- ក្រុមគាំទ្រអ្នកមើលថែ (Carer Support Groups)
- មជ្ឈមណ្ឌលសុខភាពសហគមន៍
- កិច្ចបំរើខាងម្ហូបអាហារ
- ជំនួយនៅផ្ទះ
- ការកែកុនផ្ទះ និងការថែទាំផ្ទះ (Home Maintenance & Modification)
- ការឈប់សំរាកពីការមើលថែ (Respite)
- យានជំនិះ
- កម្មវិធីអ្នកធ្វើការស្ម័គ័ចិត្រ

## តើ Carers NSW ផ្តល់កិច្ចបំរើអ្វីខ្លះ?

- ពត៌មាន និងឱវាទសំរាប់អ្នកមើលថែពីអ្នកបច្ចេកទេស (Specialist Carer Information and Advice)
- ជំនួយផ្នែកសតិអារម្មណ៍
- កម្មវិធីបណ្តុះបណ្តាល និងអប់រំ
- កម្មវិធីផ្តល់ឱវាទ (Counselling Programs)
- កញ្ចប់ឯកសារគាំទ្រអ្នកមើលថែជាភាសាខ្មែរ

NSW
Carers
AUSTRALIA

# កិច្ចបំរើសំរាប់អ្នកមើលថែនៃរដ្ឋញូសៅវែល

## តើទាក់ទងយើងដោយរបៀបណា?

លោកអ្នកអាចទាក់ទង **Carers NSW** តាមលេខទូរស័ព្ទ **1800 242 636** ។ ប្រសិនបើភាសាអង់គ្លេសមិនមែនជាភាសាកំណើតរបស់លោកអ្នកទេ លោកអ្នកអាចទាក់ទងយើងខ្ញុំតាមរយៈកិច្ចបំរើបកប្រែតាមលេខ ទូរស័ព្ទ ១៣ ១៤ ៥០ ឬមួយលោកអ្នកអាចពឹងសាច់ញាតិ ឬបុគ្គលិកអោយទាក់ទងយើងខ្ញុំជំនួសលោកអ្នក។ ប្រសិនបើសាច់ញាតិរបស់លោកអ្នកទំនេរតែពេលយប់ លោកអ្នកអាចទុកសារក្នុងម៉ាស៊ីនទទួលសារ ដោយប្រាប់ឈ្មោះរបស់លោកអ្នក លេខទូរស័ព្ទ និងភាសាដែលលោកអ្នកនិយាយ។ យើងនឹងទាក់ទងមកលោកអ្នកវិញ ដោយមានអ្នកបកប្រែ។

## តើលោកអ្នកប្តឹងតវ៉ាដោយរបៀបណា?

ប្រសិនបើលោកអ្នកជាអ្នកមើលថែ លោកអ្នកអាចនឹងមានទំនាក់ទំនងជាមួយមនុស្ស កិច្ចបំរើ និងអង្គការច្រើនប្រភេទដែលជួយលោកអ្នកជាមួយនឹងភារកិច្ចថែទាំរបស់លោកអ្នក។ ជួនកាល បញ្ហាអាចកើតឡើងដែលលោកអ្នកចង់តវ៉ា។ នៅពេលអ្វីមួយមិនមានភាពត្រឹមត្រូវ ឬលោកអ្នកជឿថាលោកអ្នក ឬអ្នកដែលលោកអ្នកមើលថែ ត្រូវបានគេប្រព្រឹត្តមិនសមរម្យមកលើលោកអ្នកមានសិទ្ធិនិយាយចេញមក ហើយសុំអោយគេដោះស្រាយបញ្ហានោះ។ ប្រសិនបើលោកអ្នកមិនច្បាស់ទេ សូមទាក់ទង **Carers NSW** តាមលេខទូរស័ព្ទ **1800 242 636** ដើម្បីពិភាក្សាបញ្ហាជាក់លាក់ណាមួយ។

DADHC
Department of Ageing, Disability & Home Care


**Carers NSW Inc.** ABN 45 461 578 851
Roden Cutler House, Level 18, 24 Campbell Street, Sydney NSW 2000 • PO Box 20156, World Square NSW 2002
P 02 9280 4744 F 02 9280 4755 E contact@carersnsw.asn.au **www.carersnsw.asn.au**
Carers line: 1800 242 636 (free call)



*Carers NSW is funded by State and Australian Governments*


*Donations over $2 are tax deductible*


2586 about - khmer